# សហភាពអន្តរសភា (IPU) និងអង្គការសហប្រជាជាតិ(UN) វាយតម្លៃខ្ពស់ចំពោះវត្តមានរបស់ស្ត្រីលើឆាកនយោបាយ



លោកស្រី Ngozi Okonjo-Iweala អគ្គនាយកអង្គការពាណិជ្ជកម្មពិភពលោក និងលោកស្រី Christine Lagarde ប្រធានធនាគារកណ្តាលអឺរ៉ុប

Vietnam+ ថ្ងៃព្រហស្បតិ៍ ៣រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៣

នៅក្នុងរបាយការណ៍មួយរបស់សហភាពអន្តរសភា(IPU) និងអង្គភាពដើម្បីសមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រីនៃអង្គការសហប្រជាជាតិ(UN-Woman) ដែលបានផ្សព្វផ្សាយកាលពីថ្ងៃអង្គារ ទី០៧ ខែមីនា ឆ្នាំ២០២៣ បានបង្ហាញថា មានស្ត្រីកាន់តែច្រើនឡើងៗមិនធ្លាប់មាន បានកាន់តំណែងដែលអាចធ្វើការសម្រេចចិត្តនយោបាយនៅទូទាំងពិភពលោក ប៉ុន្តែយ៉ាងណាក៏ដោយសមភាពយេនឌ័រនៅតែស្ថិតនៅលើផ្លូវដ៏ឆ្ងាយសែនឆ្ងាយនៅឡើយ ។

របាយការណ៍ខាងលើ បានផ្តល់នូវចំណាត់ថ្នាក់ និងការបែងចែកថ្នាក់តំបន់នៃបណ្តាប្រទេសដែលមានស្ត្រីកាន់តំណែងក្នុងតួនាទីប្រតិបត្តិ និងសភាចុងក្រោយបំផុត គិតត្រឹមថ្ងៃទី០១ខែមករាឆ្នាំ២០២៣។លទ្ធផលបានរកឃើញថា ចំនួនស្ត្រីដែលកាន់តួនាទីជាមេដឹកនាំនយោបាយបានកើនឡើងនិយាយជារួម។ ប៉ុន្តែយ៉ាងណាក៏ដោយវត្តមានរបស់ស្ត្រីក្នុងមុខតំណែងជាមេដឹកនាំជាន់ខ្ពស់ នៅក្នុងជួររដ្ឋាភិបាល ឬប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាល នៅតែមានកម្រិតទាបនៅឡើយ។ គិតត្រឹមដើមឆ្នាំ២០២៣នេះ ១១.៣% នៃបណ្តាប្រទេសទូទាំងពិភពលោកមានស្ត្រីជាប្រមុខរដ្ឋ(មិនរាប់បញ្ចូលបណ្តាប្រទេសរាជានិយម) និង៩.៨%ត្រូវបានកត់ត្រាថាជាប្រមុខរដ្ឋាភិបាល។ តួលេខទាំងពីនេះ បានកើនឡើងបើប្រៀបធៀបទៅនឹង ១ទសវត្សរ៍កន្លងមក ដែលនៅពេលនោះ មានមានស្ត្រីជាប្រមុខរដ្ឋ ត្រឹមតែ ៥.៣% និងប្រមុខរដ្ឋាភិបាលត្រឹមតែ ៧.៣% តែប៉ុណ្ណោះ។

របាយការណ៍ដដែលបានគូសបញ្ជាក់ថា មានតែ ១២ប្រទេសប៉ុណ្ណោះ នៅទូទាំងពិភពលោក ភាគច្រើននៅទ្វីបអឺរ៉ុបដែលមានគណៈរដ្ឋមន្ត្រីមានសមភាពយេនឌ័រជាមួយនឹង៥០%ឬលើសពីនេះមានសមាជិកគណៈរដ្ឋមន្ត្រីជាស្ត្រីជារដ្ឋមន្ត្រីកាន់ក្រសួងនានា ឬមានតួនាទីធំជាងនេះ។ ខណៈដែលនៅមាន ៩ប្រទេសផ្សេងទៀតនៅតែមិនមានសមាជិកគណៈរដ្ឋមន្ត្រីជាស្ត្រី ដឹកនាំក្រសួងនៅឡើយ។ បុរសនៅតែបន្តក្តោបក្តាប់ក្នុងវិស័យនយោបាយដូចជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចការពារជាតិយុត្តិធម៌និងមហាផ្ទៃ។ មានតែស្ត្រី១២%ប៉ុណ្ណោះដែលជាសមាជិកគណៈរដ្ឋមន្ត្រីបានធ្វើជារដ្ឋមន្ត្រីក្រសួងការពារជាតិ និងរដ្ឋ មន្ត្រីកិច្ចការថ្នាក់ក្រោមជាតិ។ ១១% ជារដ្ឋមន្ត្រីក្រសួងថាមពល ធនធានធម្មជាតិ ប្រេងឥន្ធនៈ និងធនធានរ៉ែ និង ៨% ជារដ្ឋមន្ត្រីក្រសួងដឹកជញ្ជូន។

លោក Martin Chungong អគ្គលេខាធិការសហភាពអន្តរសភា(IPU)បានថ្លែងថា "យើងកំពុងតែមើលឃើញពីវឌ្ឍនភាពនៃចំនួនស្ត្រីក្នុងឆាកនយោបាយនៅក្នុងឆ្នាំ២០២៣នេះ ដែលកំពុងតែត្រូវបានលើកទឹកចិត្ត។ ប៉ុន្តែយ៉ាងណាក៏ដោយយើងនៅតែស្ថិតនៅលើផ្លូវដ៏វែងឆ្ងាយនៅឡើយ ដើម្បីសម្រេចបានសមភាពយេនឌ័រ បើមើលតាមអត្រាកំណើនបច្ចុប្បន្ន"៕

*ព័ត៌មានសភាទ្វីបអឺរ៉ុប ០៩-០៣-២៣- ឈាវ សុផាត*

ប្រែសម្រួលពីៈ https://en.vietnamplus.vn/ipu-un-highly-value-womens-presence-in-politics/249515.vnp

# IPU, UN highly value women's presence in politics

More women than ever are holding political decision-making posts worldwide, but gender parity is still far off, said the Inter-Parliamentary Union (IPU) and the United Nations Entity for Gender Equality and the Empowerment of Women (UN Women) in a report released on March 7.

Hanoi (VNA) – More women than ever are holding political decision-making posts worldwide, but gender parity is still far off, said the Inter-Parliamentary Union (IPU) and the United Nations Entity for Gender Equality and the Empowerment of Women (UN Women) in a report released on March 7.

The report provides the latest rankings and regional distribution of countries with women in executive and parliamentary positions as of January 1. The results show that the number of women in political leadership roles has increased overall. However, the presence of women in high-level leadership positions in government or as heads of state and government remains very limited.

As of the beginning of this year, 11.3% of the countries worldwide had women as heads of state (excluding countries with monarchy), and 9.8% recorded women as heads of government. These both numbers increased compared to a decade ago when they were at 5.3% and 7.3%, respectively.

The report pointed out that only 13 countries, mostly in Europe, had gender-equal cabinets, with 50% or more of women cabinet members as heads of ministries and above. Meanwhile, there were still nine countries that had no women cabinet members heading ministries.

According to the report, men continued to dominate in policy areas such as economic, defence, justice, and home affairs portfolios. Women only comprise 12% of the cabinet ministers leading defence and local government portfolios, 11% of energy, natural resource fuels, and mining portfolios, and 8% of transport portfolios.

"We're seeing ongoing progress in the number of women in politics this year, which is encouraging. However, we still have a long way to go to reach gender equality when we see the current rates of growth," said IPU Secretary-General Martin Chungong./.

https://en.vietnamplus.vn/ipu-un-highly-value-womens-presence-in-politics/249515.vnp